Australian Government
Department of Health and Aged Care

medicare

Khmer




# គ្លីនិកថែទាំបន្ទាន់ Medicare - នៅទីនោះ នៅពេលដែលអ្នកត្រូវការវា

នៅទូទាំងប្រទេសអូស្ត្រាលី បណ្តាញដែលកំពុងរីកចម្រើននៃគ្លីនិកថែទាំបន្ទាន់ Medicare ផ្តល់ជូនការថែទាំសុខភាពដើរចូលដោយមិនគិតថ្លៃ សម្រាប់ជំងឺបន្ទាន់ និងការរងរបួសនានា ដោយកាត់បន្ថយសម្ពាធលើផ្នែកសង្គ្រោះបន្ទាន់ និងធ្វើឱ្យវាកាន់តែងាយស្រួលក្នុងការទទួលបានការថែទាំបន្ទាន់ នៅពេលដែលអ្នកត្រូវការវា។

គ្លីនិកថែទាំបន្ទាន់ Medicare បើកធ្វើការនៅព្រឹកព្រហាម និងបិទយឺតជារៀងរាល់ថ្ងៃ ហើយអ្នកមិនត្រូវការការណាត់ជួប ឬការបញ្ជូនបន្តទេ។ ប្រហែល 70 ភាគរយនៃប្រជាជនអូស្ត្រាលី អូស្ត្រាលីរស់នៅក្នុងចម្ងាយបើកបរ 20 នាទីពីគ្លីនិកថែទាំបន្ទាន់ Medicare។

គ្លីនិកថែទាំបន្ទាន់ Medicare គឺជាវិធីមួយដែលរដ្ឋាភិបាលអូស្ត្រាលីកំពុងវិនិយោគក្នុង Medicare ដើម្បីធ្វើឱ្យប្រាកដថា ប្រជាជនអូស្ត្រាលីមានលទ្ធភាពកាន់តែប្រសើរក្នុងការទទួលបានការថែទាំសុខភាព ការថែទាំបន្ទាន់ និងសេវាសុខភាពផ្លូវចិត្តដែលមានតម្លៃសមរម្យ។

## តើការថែទាំបន្ទាន់គឺជាអ្វី?

- **ការថែទាំទូទៅ ឬជាប្រចាំ** គឺជាអ្វីដែល GP ឬគិលានុបដ្ឋាកក្នុងតំបន់របស់អ្នកផ្តល់។
- **ការថែទាំបន្ទាន់** គឺនៅពេលដែលអ្នកមានរបួស ឬជំងឺដែលមិនអាចរង់ចាំការណាត់ជួប GP ទៀងទាត់ ប៉ុន្តែមិនមានគ្រោះថ្នាក់ដល់អាយុជីវិតនោះទេ។
- **ការថែទាំសង្គ្រោះបន្ទាន់** គឺនៅពេលដែលអ្នកមានរបួស ឬជំងឺដែលគំរាមកំហែងដល់អាយុជីវិត។

ឧទាហរណ៍នៃប្រភេទផ្សេងៗនៃការថែទាំមានបង្ហាញខាងក្រោម។

| ការថែទាំទូទៅ ឬជាប្រចាំ | ការថែទាំបន្ទាន់ | ការថែទាំសង្គ្រោះបន្ទាន់ |
|---|---|---|
| • ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺ និងរោគយ៉ាងទូលំទូលាយ<br>• ការពិនិត្យទូទៅ និងការពិនិត្យសុខភាព<br>• ការចាក់វ៉ាក់សាំង<br>• វេជ្ជបញ្ជា<br>• ដំបូន្មានសុខភាពផ្លូវចិត្ត<br>• ការណែនាំអំពីផែនការគ្រួសារ<br>• ការបញ្ជូនបន្តសម្រាប់ការធ្វើតេស្ត ការស្កេន ឬការថែទាំពីអ្នកឯកទេស<br>• ការថែទាំជំងឺរ៉ាំរ៉ៃដែលកំពុងបន្ត និងការវាយតម្លៃសុខភាព | • ការឆ្លងតិចតួច<br>• ការបាក់ឆ្អឹងតិចតួច ការគ្រេចឬផ្លោះ របួសកីឡា និងការឈឺក និងខ្នង<br>• ការឆ្លងមេរោគផ្លូវទឹកនោម (UTIs)<br>• ការរបួសតិចតួច<br>• ជំងឺឆ្លងតាមការរួមភេទ (STIs)<br>• សត្វល្អិតខាំ និងកន្ទួល<br>• ការឆ្លងមេរោគភ្នែក និងត្រចៀកតិចតួច<br>• ជំងឺផ្លូវដង្ហើម<br>• ជំងឺរលាកក្រពះពោះវៀន<br>• រលាកស្រាល | • ឈឺទ្រូង ឬតឹងណែនទ្រូង<br>• ពិបាកដកដង្ហើម<br>• ការហូរឈាមដែលមិនអាចគ្រប់គ្រងបាន<br>• រលាកធ្ងន់ធ្ងរ<br>• ការពុល<br>• ស្ពឹក ឬខ្វិន<br>• សន្លប់<br>• មិនឆ្លើយតប ឬមានការប្រកាច់<br>• គ្រុនក្តៅបន្តកើតមានចំពោះទារក<br>*ប្រសិនបើអ្នក ឬនរណាម្នាក់នៅក្នុងការថែទាំរបស់អ្នកមានរបួស ឬជំងឺដែលគំរាមកំហែងដល់អាយុជីវិត សូមទូរសព្ទទៅលេខសូន្យបីដង (000) ឬទៅកាន់ផ្នែកសង្គ្រោះបន្ទាន់ដែលនៅជិតអ្នកបំផុត។* |

## តើខ្ញុំគួរទៅគ្លីនិកថែទាំបន្ទាន់ Medicare នៅពេលណា?

ប្រសិនបើអ្នកមានរបួស ឬជំងឺដែលត្រូវការការព្យាបាល សូមសួរខ្លួនឯងថា៖

- តើវាគំរាមកំហែងដល់អាយុជីវិត ហើយតើខ្ញុំត្រូវការការថែទាំបន្ទាន់ដែរឬទេ?
- តើវាអាចរង់ចាំរហូតដល់ខ្ញុំអាចទទួលបានការណាត់ជួបដើម្បីជួប GP ក្នុងតំបន់របស់ខ្ញុំដែរឬទេ?

ប្រសិនបើវាមិនមែនជាការសង្គ្រោះបន្ទាន់ ប៉ុន្តែអ្នកមិនអាចរង់ចាំការណាត់ជួបទៀងទាត់ជាមួយ GP របស់អ្នកទេ គ្លីនិកថែទាំបន្ទាន់ Medicare នឹងវាយតម្លៃ និងព្យាបាលអ្នកនៅថ្ងៃតែមួយ។ គ្លីនិកថែទាំបន្ទាន់ Medicare បើកធ្វើការបន្ថែមម៉ោង 7 ថ្ងៃក្នុងមួយសប្តាហ៍។

## តើអ្នកណាអាចចូលប្រើគ្លីនិកថែទាំបន្ទាន់ Medicare?

គ្លីនិកថែទាំបន្ទាន់ Medicare ផ្តល់ជូនការថែទាំសុខភាពបន្ទាន់ដែលគិតថ្លៃព្យាបាលផ្ទាល់ពីរដ្ឋ (ដោយមិនគិតថ្លៃ) សម្រាប់អ្នកដែលមានប័ណ្ណ Medicare។ អ្នកមិនត្រូវការការណាត់ជួប ឬការបញ្ជូនបន្តទេ។

## តើខ្ញុំអាចរំពឹងអ្វីខ្លះនៅពេលខ្ញុំទៅគ្លីនិកថែទាំបន្ទាន់ Medicare?

នៅពេលអ្នកទៅដល់គ្លីនិកថែទាំបន្ទាន់ Medicare គិលានុបដ្ឋាកនឹងវាយតម្លៃរបួស ឬជំងឺរបស់អ្នក ដើម្បីពិនិត្យមើលថាតើវាបន្ទាន់ប៉ុណ្ណាដែរ។ នេះគឺជាប្រព័ន្ធ ‘វាយតម្លៃភាពបន្ទាន់នៃការព្យាបាលអ្នកជំងឺ’ ដែលត្រូវបានប្រើដើម្បីសម្រេចថាតើអ្នកជំងឺណាដែលចាំបាច់ទៅជួបវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាកមុនគេ។

មនុស្សដែលមានស្ថានភាពធ្ងន់ធ្ងរបំផុត អាចត្រូវបានពិនិត្យមុនអ្នកផ្សេងទៀតដែលបានរង់ចាំយូរជាងនេះ ឬអ្នកដែលមានការណាត់ជួប។ នេះធានាថាករណីបន្ទាន់បំផុតត្រូវបានព្យាបាលមុន។

## ព័ត៌មានបន្ថែម

**ដើម្បីស្វែងរកគ្លីនិកថែទាំបន្ទាន់ Medicare ដែលនៅជិតអ្នកបំផុត សូមចូលទៅកាន់គេហទំព័រ health.gov.au/MedicareUCC**

**សម្រាប់ព័ត៌មានអំពីរបៀបដែល Medicare អាចជួយអ្នកបាន សូមចូលទៅកាន់គេហទំព័រ medicare.gov.au/stronger**

ស្កេនដើម្បីស្វែងយល់បន្ថែម